# ពុទ្ធបាទ៤រូត[១]

## ១- ព័ត៌មានទូទៅ

ព្រះពុទ្ធជាមហាបុរសដ៏ប្រសើរទ្រង់មានសណ្ឋានអវៈយវៈព្រះរូប ព្រះកាយ ខុសពីមនុស្សធម្មតាតួយ៉ាងដូចជាកម្ពស់របស់ព្រះអង្គប្រវែង១៨ហត្ថ ព្រះហស្តវែងដល់ជង្គង់ ព្រះបាទទាំងគូមានផ្ទៃរាបស្មើ មានរូបចក្រប្រកបដោយកាំមួយពាន់ស្មើគ្នា[២]។ នៅក្នុងព្រះបាទទាំងពីររបស់ព្រះពុទ្ធមានរូបសត្វ វត្ថុ ទេវតា ព្រហ្ម ដែលគេសន្មតថាជារូបមង្គលហៅថាមង្គល១០៨។ រូបទាំង១០៨នេះមិនមានសម្ដែងក្នុងគម្ពីរព្រះត្រៃបិដកឡើយ លុះសម័យតែងអដ្ឋកថា ទើបមានសេចក្ដីពន្យល់និងបង្ហាញរូបទាំងនេះ[៣]។ រីឯទីតាំងដែលព្រះពុទ្ធប្រតិស្ឋានពុទ្ធបាទមានសម្ដែងនៅក្នុងអដ្ឋកថាបុណ្ណោវាទសូត្រ នៅពេលព្រះអង្គយាងទៅប្រោសព្រះបុណ្ណៈទ្រង់បានប្រថាប់ស្នាមព្រះបាទពីរកន្លែងគឺលើភ្នំសច្ចពន្ធ និងស្ទឹងនម្មទា (សព្វថ្ងៃជាទឹកដីប្រទេសភូមា)។ នៅក្នុងអដ្ឋកថាធម្មបទ ខុទ្ទកនិកាយ ត្រង់រឿងមាគន្ទិយាព្រាហ្មណ៍ព្រះអង្គបានប្រថាប់ម្ដងទៀតប៉ុន្តែរលុបទៅដោយការអធិដ្ឋាន។ ក្នុងពង្សាវតារមហាវង្សស្រីលង្កាបានបញ្ជាក់ចំនួនពុទ្ធបាទមានបីកន្លែងគឺនៅលើភ្នំសុមនកូដ ឬស្រីបាទ ភ្នំសច្ចពន្ធ ស្ទឹងនម្មទា។ បើតាមគម្ពីរទាំងអស់នេះពុទ្ធបាទមានតែ៣ឋានប៉ុណ្ណោះ។ ចំណែករឿងអក្សរសិល្ប៍បាលីប្រទេសថៃបានអះអាងថាពុទ្ធបាទមាន៥ឋាន គឺស្ទឹងនម្មទា ភ្នំសច្ចពន្ធ ភ្នំសុមនកូដ ភ្នំសុវណ្ណមាលិក យោនកបុរី តាមរយៈពាក្យកាព្យបាលីវន្ទាមិពុទ្ធបាទ និងពាក្យកាព្យខ្មែរ ពុទ្ធបាទ៥ឋាន ថ្វាយបាយបត្តបូរ សរសើរពុទ្ធស្តាំ សរសើរពុទ្ធបាទឆ្វេង។ ពុទ្ធបាទបន្ថែមពីរកន្លែងក្រោយនេះមិនមែនជាពុទ្ធដែលព្រះពុទ្ធប្រតិស្ឋានទេ ហើយគ្មានសម្ដែងក្នុងគម្ពីរព្រះត្រៃបិដកនិងអដ្ឋកថា ជាកាព្យបាលីរបស់អ្នកស្រុកយោនក

[១] ខ្ញុំប្រើពាក្យរូតព្រោះមានន័យត្រូវជាងពាក្យ ឋាន។ម្យ៉ាងកុំឱ្យច្រឡំនឹងពុទ្ធបាទ៥ឋាន។

[២] សូមអាន៖ ពុទ្ធសាសនបណ្ឌិត្យ, សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ១៩,ភ្នំពេញ, ឆ្នាំ១៩៦០

[៣] សូមអាន៖ ភួន់ ភ្វី, ជឹម សុវិទ្យា, ស្នាមព្រះបាទនៅប្រទេសភូមា, បាត់ដំបង, ឆ្នាំ២០១៦

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

បុរីតែងសម្រាប់សូត្រមនស្សការពុទ្ធបាទតែប៉ុណ្ណោះ[៤]។ រូបរាងពុទ្ធបាទមានពីរគឺៈពុទ្ធបាទ ១រួតគឺជាស្នាមបាទាព្រះពុទ្ធអង្គមានរូបកង់ចក្រនៅកណ្ដាលនិងរូបមង្គលក៏មាន គ្មានរូបកង់ចក្រមាន រូបមង្គលក៏មាន មានត្រឹមស្នាមជើងក៏មាន។ ពុទ្ធសិល្បៈពុទ្ធបាទប្រភេទនេះគឺមាននៅប្រទេសឥណ្ឌា ភូមា ស្រីលង្កា ខ្មែរ ថៃដូចគ្នា(រូបលេខ១,២,៣,៤,៥)។



រូបលេខ១




រូបលេខ២ប្រភពៈ The significance of the Buddha Footprint Bagan Metropolis



រូបលេខ៣



រូបលេខ៤ប្រភពៈ អដ្ឋាធរជាតិអប្បរា



រូបលេខ៥ប្រភពៈ พิพิธภัณฑสถานแห่งชาติ อู่ทอง

៤ JUAN KONGKAEW The Buddhist art in Buddha‘s footprint. Thai 2016

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

ពុទ្ធបាទម្យ៉ាងទៀតគឺពុទ្ធបាទ៤រួតដែលជាស្នាមបាទារបស់ព្រះពុទ្ធត្រួតលើគ្នា៤ជាន់មានរូបចក្រកណ្តាលព្រះបាទរូបមង្គល១០៨នៅជុំវិញ(រូបលេខ២៦)។



រូបលេខ២៦ប្រភព៖รอยพระพุทธบาทจำลอง

## ២- ប្រវត្តិពុទ្ធបាទ៤រួត

ពុទ្ធបាទ៤រួតជាពុទ្ធសិល្បៈថ្មី កើតនៅប្រទេសថៃចុងពុទ្ធសតវត្សរ៍ទី១៩ក្នុងសម័យសុខោទ័យមានបួនកន្លែងគឺនៅសុខោទ័យ ស្រីសញ្ជនាល័យ បាងផាន និងព្រះបាងដោយយកគម្រូតាមពុទ្ធបាទនៅភ្នំសុមនកូដក្នុងរជ្ជកាលស្តេចលង្កាព្រះនាម ព្រះមហាធម្មរាជាលិទៃ[៥]។ ពុទ្ធបាទប្រភេទនេះប្រទេស ឥណ្ឌា ភូមា លង្កា ដែលជាប្រទេសប្រតិបត្តិព្រះពុទ្ធសាសនាតាំងពីបុរាណមកមិនមានឡើយ ប៉ុន្តែនៅប្រទេសថៃនិទានតំណាលពីព្រះពុទ្ធសមណគោត្តមនិមន្តទៅប្រោសវេនេយ្យសត្វនៅបច្ចន្តប្រទេស[៦] ជាមួយភិក្ខុសង្ឃ៥០០អង្គ

[៥] ជាសេចក្តីអត្ថាធិប្បាយប្រវត្តិពុទ្ធបាទនៅវត្តព្រះពុទ្ធបាទរាជវរមហាវិហារខេត្តស្រះបុរីប្រទេសថៃ។

[៦] ក្នុងច្បាប់និទានថៃបញ្ជាក់ថាជាប្រទេសថៃ។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ទ្រង់យាងដល់ភ្នំវេភារៈបព៌តក៏ទតយល់ស្នាមពុទ្ធបាទ ដែលព្រះពុទ្ធ៣អង្គបានត្រាស់ដឹងក្នុងកន្លងមកជាន់ទុកក្នុងទីនោះហើយព្រះអង្គក៏បរិវិតក្កពិចារណាឃើញថាជាពុទ្ធវិន័យពីបុរាណទើបព្រះអង្គប្រតិស្ឋានស្នាមព្រះបាទមួយទៀត ត្រួតពីលើស្នាមព្រះបាទរបស់ព្រះពុទ្ធមុនៗ ទើបព្រះអង្គត្រាស់ទៅភិក្ខុសង្ឃទាំង៥០០អង្គក្នុងទីនោះឱ្យស្គាល់ថាកន្លែងជាតម្កល់ពុទ្ធបាទរបស់ព្រះសម្មាសម្ពុទ្ធទាំង៥ព្រះអង្គក្នុងភទ្រកប្បនេះគឺ ព្រះពុទ្ធកក្កុសន្ធៈ ព្រះពុទ្ធកោនាគមនៈ ព្រះពុទ្ធកស្សបៈ ព្រះសមណគោត្តម ព្រះអរិយមេត្តេយ្យៗក្រោយពីព្រះសមណគោត្តមបរិនិព្វានបាន២០០០ឆ្នាំក៏មានអព្ភូតហេតុកើតឡើងនៅលើភ្នំវេភារធ្វើឱ្យប្រជារាស្ត្រ ស្តេចក្នុងក្រុងឈៀងម៉ៃ ដឹងថាមានពុទ្ធបាទនៅលើកំពូលភ្នំក៏នាំគ្នាទៅបូជានមស្សការពុទ្ធបាទរហូតដល់រជ្ជកាលស្តេចក្រោយធ្វើមណ្ឌបគ្របពីលើពុទ្ធបាទៗ លុះមកដល់ពុទ្ធសករាជ២៤៧២ទើបមានព្រះសង្ឃជនជាតិលានណា និងបរិស័ទ៥០០នាក់ទៅរុះរើមណ្ឌបចាស់ធ្វើមណ្ឌបថ្មីគ្របពីលើពុទ្ធបាទៗ

### ៣- ពុទ្ធសិល្បៈពុទ្ធបាទ៤រួត

បណ្តាពុទ្ធបាទនៅប្រទេសឥណ្ឌា លង្កា ភូមា ខ្មែរ និងថៃ យើងឃើញមានតែ២ប្រទេសប៉ុណ្ណោះក្នុងចំណោមប្រទេសដែលកាន់ព្រះពុទ្ធសាសនាគឺប្រទេសថៃនិងប្រទេសខ្មែរដែលមានពុទ្ធសិល្បៈពុទ្ធបាទ៤រួត ព្រោះពុទ្ធសិល្បៈប្រភេទនេះបង្កើតឡើងផ្សារភ្ជាប់ជាមួយនិទានរបស់អ្នកស្រុកឈៀងម៉ៃនៅចុងពុទ្ធសតវត្សរ៍ទី១៩ៗ ដូច្នេះហើយទម្រង់ពុទ្ធសិល្បៈពុទ្ធបាទនេះមានលក្ខណៈខុសគ្នាពីសម័យមួយទៅសម័យមួយ(រូបលេខ៧- ១១)ៗ




រូបលេខ៧ប្រភពៈ พิพิธภัณฑสถานแห่งชาติอู่ทอง

អត្ថបទដោយៈ រឹម ទិត្យបញ្ញា




រូបលេខ៨ប្រភព៖ PAPAIWAT




រូបលេខ៩ប្រភព៖ พิพิธภัณฑสถานแห่งชาติ อู่ทอง




រូបលេខ១០ប្រភព៖
พิพิธภัณฑสถานแห่งชาติ อู่ทอง




រូបលេខ១១ ប្រភព៖
RAMKHAMHAENGMUSEUM

ពុទ្ធសិល្បៈពុទ្ធបាទនៅប្រទេសខ្មែរ ទើបតែប្រទះឃើញនៅពាក់កណ្ដាលសតវត្សរ៍ទី២០ក្នុងបណ្ណាល័យវត្តទីឃវ័ន(ព្រៃវែង)ស្ថិតនៅសង្កាត់ពងទឹកខណ្ឌដង្កោ រាជធានីភ្នំពេញ(អតីតបុរាណដ្ឋាន)ប្រភេទថ្មថ្មើមអណ្ដើកសាងឡើងនៅឆ្នាំ១៩២៩។ (រូបលេខ១២,១៣)។



រូបលេខ១២៖បានសាងព្រះបាទនេះក្នុងឆ្នាំ១៩២៩

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ១៣

សរុបមកពុទ្ធសិល្បៈពុទ្ធបាទជានិមិត្តរូបនៃព្រះពុទ្ធអង្គសម្រាប់ពុទ្ធសាសនិកគោរពបូជានៅសម័យបុរាណរហូតមកដល់បច្ចុប្បន្ន។ ពុទ្ធបាទជាសាសនវត្ថុមួយក្នុងចំណោម៥ ដែលព្រះពុទ្ធបានកំណត់ឱ្យបរិស័ទគោរពប្រណិប័តន៍តាងព្រះអង្គ។ ចំណែកពុទ្ធសិល្បៈពុទ្ធបាទកើតឡើងនៅថៃប្រទេសនិងវិវត្តន៍ជាបែបផែនផ្សេងៗ ពីទម្រង់ពុទ្ធសិល្បៈដើមទៅតាមការនិយមនិងគំនិតច្នៃប្រឌិតតាមសម័យកាលនីមួយៗ។ ចំពោះប្រទេសខ្មែរក៏ទទួលយកគម្រូពុទ្ធបាទប្រភេទនេះរួមផ្សំនឹងអ្វីខ្លួនមានបង្កើតបានជាសិល្បៈមួយបែបទៀត។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

# ឯកសារពិគ្រោះ


ភួន់ ភ្វី, ជឹម សុវិទ្យា

ស្នាមព្រះបាទនៅប្រទេសភូមា, បាត់ដំបង, ឆ្នាំ២០១៦

ពុទ្ធសាសនបណ្ឌិត្យ

សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ១៩,ភ្នំពេញ, ឆ្នាំ១៩៦០

SU LATT WIN

2017. The significance of the Buddha Footprint Bagan Metropolis. london

JUAN KONGKAEW

2016. The Buddhist art in Buddha‘s footprint. Thai

TRENT THOMAS WALKER

2018. Unfolding Buddhism Communal Scripts, Localized Translation, and the Work of the Dying in Cambodian Chanted Leporellos.

RAMKHAMHAENGMUSEUM

finearts.go.th/ramkhamhaengmuseum/view/7857-โบราณวัตถุชิ้นเด่น--พระพุทธบาทสี่รอย

https://www.mcu.ac.th/article/detail/14310